# អនុក្រឹត្យ

## ស្តីពី

## បែបបទសំរាប់អនុវត្តចំពោះការអនុញ្ញាតអោយជនបរទេសអន្តោរប្រវេសន៍ចេញ ចូល និងស្នាក់អាស្រ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា

๑๐๖๒

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## បែបបទសំរាប់អនុវត្តចំពោះការអនុញ្ញាតអោយ ជនបរទេសអន្តោប្រវេសន្តចេញ ចូល និង ស្នាក់អាស្រ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាល**

_បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២

_បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

_បានឃើញព្រះរាជក្រមលេខ០២ នស_៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

_បានឃើញព្រះរាជក្រឹត្យលេខ នស_រកត_១០៩៤_៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

_បានឃើញព្រះរាជក្រឹត្យលេខ នស_រកត_១០៩៤_៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

_បានឃើញព្រះរាជក្រមលេខ នស_រកម_០១៩៦_០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

_បានឃើញ ច្បាប់ស្តីពីអន្តោប្រវេសន៍ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ០៥ ន / ស ៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤

_បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

_តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

_តាមការយល់ព្រមនៃគណៈរដ្ឋមន្ត្រី

**សំរេច**

## ជំពូកទី១
## បទបញ្ញត្តិទូទៅ

មាត្រា១ .-ជនបរទេសអន្តោប្រវេសន្ត គឺជនបរទេសណាដែលបានកំណត់ក្នុងជំពូកទី៣ នៃច្បាប់ស្តីពីអន្តោប្រវេសន៍ ។

មាត្រា២ .-អនុក្រឹត្យនេះកំណត់ពីបែបបទសំរាប់ការអនុញ្ញាតអោយជនបរទេសអន្តោប្រវេសន្ត ចេញ ចូល និង ស្នាក់អាស្រ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី២
## បែបបទក្នុងការសុំទទួលយកក្នុងព្រះរាជាណាចក្រកម្ពុជា

មាត្រា៣ .-ជនបរទេសដែលមានបំណងមកស្នាក់អាស្រ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាជនបរទេសអន្តោប្រវេសន្ត អាចដាក់ពាក្យសុំបានមកក្រសួងមហាផ្ទៃ តែតាមរយៈអាជ្ញាធរទូត ឬ កុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ឬ តែតាមរយៈអាជ្ញាធរបរទេសណាមួយដែលតំណាងអោយផលប្រយោជន៍នៃព្រះរាជាណាចក្រកម្ពុជា នៅក្រៅប្រទេសដោយ ៖

១-ត្រូវបំពេញបែបបទមិដ្ឋាការ ។

២-ត្រូវភ្ជាប់មកជាមួយនូវសេចក្តីចម្លងលិខិតឆ្លងដែនរបស់ខ្លួន ឬ សេចក្តីចម្លងឯកសារធ្វើដំណើរណាមួយ ដែលមានតម្លៃស្មើគ្នា ដែលមានសុពលភាពយ៉ាងតិច៦ខែ មុនថ្ងៃចូលព្រះរាជាណាចក្រកម្ពុជា ។

៣-ត្រូវមានរូបថតទំហំ ៤ x ៦ ចំនួន ៣សន្លឹក ថតចំពីមុខ គ្មានពាក់មួក និង មិនពាក់វ៉ែនតាពណ៌ ។

៤-ត្រូវមានវិញ្ញាបនប័ត្របញ្ជាក់សុខភាពចំនួនមួយច្បាប់ ដែលចេញអោយដោយវេជ្ជបណ្ឌិត នៃប្រទេសដើមរបស់ខ្លួន ។ វិញ្ញាបនប័ត្រនេះ ត្រូវមានកាលបរិច្ឆេទមិនហួសពី៣ខែ នៅពេលដាក់ពាក្យ ។

៥-ត្រូវមានភស្តុតាងបញ្ជាក់អំពីការមានមធ្យោបាយគ្រប់គ្រាន់សំរាប់ចិញ្ចឹមជីវិតផ្ទាល់ខ្លួន និង សមាជិកក្នុងបន្ទុកខ្លួនបាន និង មានអ្នកធានាក្នុងស្រុកដែលមានសមត្ថភាព និង លទ្ធភាពទទួលខុសត្រូវខាងជីវភាព និង មធ្យោបាយផ្គត់ផ្គង់ផ្សេងៗទៀត ។

៦-ត្រូវមានលិខិតថ្កោលទោស ដែលចេញអោយដោយអាជ្ញាធរមានសមត្ថកិច្ច នៃប្រទេសដើមរបស់ខ្លួន ។

៧-ត្រូវមានសេចក្តីចម្លងកិច្ចសន្យាការងារជាមួយឯកជនដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជាមួយច្បាប់ បើសិនជាមាន ។

៨-ត្រូវមានសលាកប័ត្រ ស្តីពីការតម្កល់ប្រាក់ធានាសំរាប់ថ្លៃសោហ៊ុយធ្វើដំណើរត្រឡប់ទៅវិញ ឬ មាតុភូមិនិវត្តន៍ ជាយថាហេតុចំពោះ ៖

ក-ជនបរទេសដែលមកពីប្រទេស ដែលមានព្រំប្រទល់ជាប់នឹងព្រះរាជាណាចក្រកម្ពុជា ចំនួនប្រាំសែនរៀល (៥០០.០០០,០០) ។

ខ-ជនបរទេសដែលមកពីអាស៊ី និង អូសេអានីចំនួនមួយលានពីរសែនប្រាំម៉ឺនរៀល (១.២៥០.០០០,០០) ។

គ-ជនបរទេសដែលមកពីមជ្ឈិមបូព៌ា និង អាហ្វ្រិកចំនួនពីរលានប្រាំសែនរៀល (២.៥០០.០០០,០០) ។

ឃ-ជនបរទេសដែលមកពីអឺរ៉ុប និង អាមេរិកចំនួនបីលានប្រាំពីរសែនប្រាំម៉ឺនរៀល (៣.៧៥០.០០០,០០) ។

ប្រាក់នេះត្រូវតម្កល់នៅធនាគារជាតិនៃកម្ពុជា ហើយអាចដកវិញបានលុះណាតែមានការអនុញ្ញាតពីក្រសួងមហាផ្ទៃ ។

ជនបរទេសដែលមានសហព័ទ្ធ ឬ កូនជាអនីតិជនអាយុតិចជាង១៨ឆ្នាំ មានបំណងស្នើសុំជាជនបរទេសអន្តោប្រវេសន្ត អាចធ្វើពាក្យស្នើសុំនោះជាចង្កោមគ្រួសារ។

(x) ក្នុងករណីពាក្យស្នើសុំនោះបានទទួលការយល់ព្រម សាមីជនត្រូវបង់ថ្លៃអាករទិដ្ឋាការចំនួនពីរសែនប្រាំម៉ឺនរៀល (២៥០.០០០,០០) ក្នុងសមាជិកគ្រួសារម្នាក់។ លើកលែងតែកុមារអាយុ១២ឆ្នាំចុះត្រូវបង់ចំនួនមួយសែនពីរម៉ឺនប្រាំពាន់រៀល (១២៥.០០០,០០) ក្នុងកុមារម្នាក់ ។

មាត្រា៤ .-អនីតិជន សហព័ទ្ធដែលរួមរស់ជាមួយគ្នា និង អាស្រ័យពឹងពាក់គ្នាខាងផ្លូវកាយ និង ខាងហិរញ្ញវត្ថុ ក្នុងលក្ខណៈជាសមាជិកគ្រួសារបង្កើតស្និទ្ធ ក៏អាចត្រូវទទួលបានការអនុញ្ញាតអោយធ្វើអន្តោប្រវេសន៍ បានដែរ នៅពេលដែលជនបរទេសអន្តោប្រវេសន្តណាមួយត្រូវបានទទួលស្គាល់ហើយនោះ ។

មាត្រា៥ .-ការទទួលស្គាល់ជនបរទេសណាមួយជាជនបរទេសអន្តោប្រវេសន្តត្រូវសំរេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី៣

## ការស្នាក់នៅ ការងារ និង ការចេញ ចូល

មាត្រា៦ .-ជនបរទេសដែលត្រូវបានទទួលស្គាល់ ជាជនបរទេសអន្តោប្រវេសន្ត ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវសុំប័ណ្ណស្នាក់នៅ នៅការិយាល័យជនបរទេស នៃស្នងការដ្ឋាននគរបាលខេត្ត ក្រុង ក្នុងរយៈពេល៤៨ ម៉ោង បន្ទាប់ពីបានមកដល់ព្រះរាជាណាចក្រកម្ពុជា ។

មាត្រា៧ .-ជនបរទេសអន្តោប្រវេសន្ត ត្រូវសុំប័ណ្ណការងារតាមការកំណត់នៃច្បាប់ការងាររបស់ព្រះរាជាណាចក្រកម្ពុជា ។

មាត្រា៨ .-ជនបរទេសអន្តោប្រវេសន្ត ដែលមានបំណងចាកចេញពីព្រះរាជាណាចក្រកម្ពុជា ជាបណ្តោះអាសន្នត្រូវសុំការអនុញ្ញាតពីក្រសួងមហាផ្ទៃ ។ បែបបទនៃការស្នើសុំមានដូចតទៅ ៖

១-ត្រូវបំពេញពាក្យសុំចេញពីព្រះរាជាណាចក្រកម្ពុជាតាមរយៈស្នងការនគរបាលខេត្ត ក្រុង ។

២-ត្រូវភ្ជាប់មកជាមួយនូវសេចក្តីចម្លងលិខិតឆ្លងដែនរបស់ខ្លួន ឬ សេចក្តីចម្លងឯកសារធ្វើដំណើរ ។

៣-ត្រូវផ្តល់លិខិតថតចម្លងប័ណ្ណស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាចំនួនមួយច្បាប់ ។

៤-រូបថតទំហំ ៤ x ៦ មួយសន្លឹក "ថតចំពីមុខ គ្មានពាក់មួក និង វ៉ែនតាពណ៌" ។

៥-ត្រូវបង់អាករទិដ្ឋាការចេញ-ចូល មួយលើកចំនួនប្រាំម៉ឺនរៀល (៥០.០០០៛០០) ។

កុមារមានអាយុ១២ឆ្នាំចុះ ធ្វើដំណើរជាមួយឪពុក ម្តាយ ឬ អាណាព្យាបាលមិនចាំបាច់បំពេញបែបបទដោយឡែកទេ តែត្រូវចុះឈ្មោះ និង បិទរូបថតជាមួយឪពុក ម្តាយ ឬ អាណាព្យាបាល ។ កុមារជាអនីតិជនដែលធ្វើដំណើរទោលតែឯង ត្រូវបង្ហាញលិខិតអនុញ្ញាតអោយចេញ ដែលចុះហត្ថលេខាដោយអាណាព្យាបាល ឬ ឪពុក ម្តាយស្របច្បាប់របស់គេ ។

មាត្រា៩ .-ជនបរទេសអន្តោប្រវេសន្ត ដែលបានបំពេញបែបបទដូចមានចែងក្នុងមាត្រា៨ ខាងលើ អាចទទួល ការបោះត្រា "អនុញ្ញាតអោយចេញ ចូល ច្រើនដង" នៅលើលិខិតឆ្លងដែន ឬ ឯកសារធ្វើដំណើរ ។ រយៈពេលនៃការអនុញ្ញាតអោយចេញ ចូល ច្រើនដងនោះមិនត្រូវអោយលើសពីបីខែឡើយ ។

អាករទិដ្ឋាការ "អនុញ្ញាតអោយចេញ ចូល ច្រើនដងត្រូវកំណត់" ចំនួនបីសែនរៀល (៣០០.០០០៛០០) ។

មាត្រា១០ .-អាករគ្រប់ប្រភេទខាងលើ ត្រូវបង់ចូលថវិកាជាតិ ។

បែបបទនៃការប្រមូលអាករនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងមហាផ្ទៃ ។

## ជំពូកទី៤

## ការដកហូតលក្ខណសម្បត្តិជាជនបរទេសអន្តោប្រវេសន្ត

មាត្រា១១ .-អាចត្រូវដកហូតលក្ខណសម្បត្តិជាជនបរទេសអន្តោប្រវេសន្តដោយប្រកាសរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចំពោះជនបរទេសអន្តោប្រវេសន្តណា ដែលបានប្រព្រឹត្តល្មើសនឹងអនុបញ្ញត្តិនៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ហើយដែលត្រូវតុលាការផ្តន្ទាទោសឧក្រិដ្ឋចាប់ពី៥ឆ្នាំឡើងទៅ ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

មាត្រា១២ .-បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា១៣ .-សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន រដ្ឋលេខាធិការមុខងារសាធារណៈ គ្រប់ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យ នេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ១៩៩៦

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

នរោត្តម រណឫទ្ធិ ហ៊ុន សែន

បានបង្គំទូលថ្វាយ និង ជំរាបជូន

សម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១ និង សម្តេចនាយករដ្ឋមន្ត្រីទី២

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង យូ ហុកគ្រី

កន្លែងទទួល

-ខុទ្ទកាល័យព្រះមហាក្សត្រ
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គនាយកដ្ឋានព្រះបរមរាជវាំង
-ខុទ្ទកាល័យសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២
-ដូចមាត្រា១៣
-ឯកសារ-កាលប្បវត្តិ